# របាយការណ៍សង្ខេបស្តីពីការតាមដាន និងការអនុវត្តគម្រោង ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ដែលបណ្តាលមកពីការបាត់បង់ និងរេចរិលព្រៃឈើ (រេដបូក) នៅក្នុងដែនជម្រកសត្វព្រៃកែវសីមានៃប្រទេសកម្ពុជា





| | |
|---|---|
| ឈ្មោះគម្រោង | គម្រោងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ដែលបណ្តាលមកពីការបាត់បង់ និង រេចរិលព្រៃឈើនៅក្នុងដែនជម្រកសត្វព្រៃកែវសីមា |
| ឯកសារផ្សព្វផ្សាយ | ៣.៣- ឯកសារសង្ខេបស្តីពីការតាមដាន និងការអនុវត្តគម្រោងរេដបូកក្នុងដែនជម្រកសត្វព្រៃកែវសីមា |
| កាលបរិច្ឆេទចេញផ្សាយ | ២២-តុលា-២០១៨ |
| រៀបរៀងដោយ | អង្គការសមាគមអភិរក្សសត្វព្រៃតំណាងឱ្យក្រសួងបរិស្ថាននៃរាជរដ្ឋាភិបាលកម្ពុជា |
| ទំនាក់ទំនង | ក្រសួងបរិស្ថាន៖ ឯកឧត្តម បណ្ឌិត ជួប បារីស (H.E. Dr. Paris Choup) ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព paris.ncgg@gmail.com, www.moe.gov.kh<br>អង្គការសមាគមអភិរក្សសត្វព្រៃ៖បណ្ឌិត កែន សេរីរដ្ឋា (Dr. Sereyrotha Ken)<br>sken@wcs.org, www.wcscambodia.org |

| | |
|---|---|
| ឈ្មោះគម្រោង | គម្រោងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ដែលបណ្តាលមកពីការបាត់បង់ និង រេចរិលព្រៃឈើនៅក្នុងដែនជម្រកសត្វព្រៃកែវសីមា |
| ទីតាំងគម្រោង | តំបន់ដែនជម្រកសត្វព្រៃកែវសីមា ខេត្តមណ្ឌលគិរី និងក្រចេះ ព្រះរាជាណាចក្រកម្ពុជា |
| ម្ចាស់គម្រោង | ក្រសួងបរិស្ថាន រាជរដ្ឋាភិបាលកម្ពុជា<br>ទំនាក់ទំនង: ឯកឧត្តមបណ្ឌិត ជួប ប៉ារីស, ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព paris.ncgg@gmail.com, +855 23 213 908 |
| រយៈពេលគម្រោង | ការបរិច្ឆេទនៃការចាប់ផ្តើមគម្រោង: ១ មករា ២០១០<br>កំឡុងពេលគណនាឧស្ម័នផ្ទះកញ្ចក់ និង រយៈពេលនៃគម្រោង: ៦០ ឆ្នាំ |
| បទដ្ឋាន CCB | CCBA. 2013. Climate, Community & Biodiversity Standards Third Edition.<br><br>CCBA, Arlington, VA, USA. December, 2013. |
| ប្រវត្តិនៃការផ្ទៀងផ្ទាត់គម្រោង | • ការផ្ទៀងផ្ទាត់លើទីមួយ ឆ្នាំ ២០១០ ដល់ ឆ្នាំ ២០១៥ (ខែ ធ្នូ ២០១៥)<br>• ការផ្ទៀងផ្ទាត់លើទីពីរ ឆ្នាំ ២០១៦ ដល់ ឆ្នាំ ២០១៨ (ខែ កញ្ញា ២០១៨) |
| សេចក្តីសង្ខេប | ទទួលបានការផ្តល់សុពលភាព CCBA ដំបូង (ពេញលេញ), ដោយប្រើស្តង់ដារ CCBA ដែលបានបោះពុម្ពលើកទីបី។<br>**អត្ថប្រយោជន៍អាកាសធាតុ**<br>•គម្រោងនេះត្រូវបានរំពឹងថានឹងមានលទ្ធផលនៅក្នុងការកាត់បន្ថយការបំភាយនៃឧស្ម័នកាបូនិច ១០លានតោន (tCO2e ១០ លាន) ពីការជៀសវាងនូវការបាត់បង់ព្រៃឈើដោយពុំបានរៀបចំគ្រោងទុកជាមុន ក្នុងរយៈពេល ១០ ឆ្នាំខាងមុខ។<br>**អត្ថប្រយោជន៍សហគមន៍**<br>•ការពារតំបន់ព្រៃឈើដែលផ្តល់នូវតម្រូវការជាមូលដ្ឋាន និងអត្តសញ្ញាណវប្បធម៌ ប្រពៃណី ២ ៥០០ គ្រួសារ (ប្រមាណ ១២៥ ០០០ នាក់) នៅក្នុងភូមិដែលចូលរួមក្នុងគម្រោងរេដបូកទាំង ២០ភូមិ។<br>•ពង្រឹងសិទ្ធិកាន់កាប់ និងកាត់បន្ថយភាពគ្មានដីធ្លីរបស់សហគមន៍នៅក្នុងតំបន់ព្រៃសីមាតាមរយៈការធ្វើផែនការគាំទ្រផ្នែកចុះបញ្ជីកម្មសិទ្ធិដីសហគមន៍ស្របច្បាប់សម្រាប់ជនជាតិដើមភាគតិច (ICT) ការចូលរួមការធ្វើផែនការប្រើប្រាស់ដីធ្លី (PLUP) និងកិច្ចព្រមព្រៀងប្រើប្រាស់ដី។<br>•គាំទ្រការចិញ្ចឹមជីវិតផ្សេងៗ ដែលអាចជួយកាត់បន្ថយការបាត់បង់ព្រៃឈើ ការផ្តល់ឱកាសបង្កើតប្រាក់ចំណូល និងការអភិវឌ្ឍជំនាញ។ នេះរួមបញ្ចូលទាំងអក្ខរកម្ម និងអប់រំសម្រាប់បង្កើនជីវភាពរស់នៅក្រៅពីមុខរបរកសិកម្ម។<br>•ផ្តល់បន្ថែមនូវការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងការគាំទ្រហេដ្ឋារចនាសម្ព័ន្ធដើម្បីបង្កើននូវសន្តិសុខស្បៀង ប្រាក់ចំណូល និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។<br>•ការចែករំលែកផលប្រយោជន៍ដោយផ្ទាល់នូវប្រាក់ចំណូលពីការលក់កាបូន ក្នុងការគាំទ្រដល់វិស័យអាទិភាពសម្រាប់ការវិនិយោគរបស់សហគមន៍។<br>**អត្ថប្រយោជន៍ជីវចម្រុះ**<br>•ក្នុងកំឡុងពេលដប់ឆ្នាំដំបូងនេះ គម្រោងរេដបូក នឹងទប់ស្កាត់ការបាត់បង់នូវព្រៃអណ្តាមភាគខាងត្បូង និងព្រៃ |

| | |
|---|---|
| | ល្បោះទំនាបសម្បូរប្រភេទពពួកឈើទាល (dipterocarp)ជិត ៣០ ០០០ ហិកតា ។ តំបន់គម្រោង ១៦៦ ៩៨៣ ហិកតា គឺជាប្លុកដ៏ធំបំផុតនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ និងរងគម្រាមកំហែងទាំងនេះ។<br>•គម្រោងនេះនឹងធានាឱ្យបាននូវភាពធន់ទ្រាំនៃតំបន់ជាពិសេសជាជម្រកមានមុខងារសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងនូវការរេចរិល និងការរំខានដោយមនុស្សតិចតួច។ ដូចគ្នានេះដែរ គម្រោងនេះនឹងធានាឱ្យបាននូវភាពធន់ទ្រាំ និងការកើនឡើងវិញនៃប្រភេទសត្វជាច្រើនដែលជាការព្រួយបារម្ភនៃការអភិរក្សជាសកល។ ប្រភេទសត្វដែលគួរឱ្យកត់សម្គាល់មួយចំនួនរួមមានដំរីអាស៊ី ចំនួននៅសល់ធំជាងគេបំផុតនៅលើពិភពលោកនៃស្វាកន្ទុយសខ្មៅ ទោចថ្គាល់លឿង ខ្ទីង ទន្សោង និងក្ងោក។<br>**កម្រិតជីវចម្រុះមាស**<br>•គម្រោងរេដបូកសីមាមានលក្ខណៈគ្រប់គ្រាន់ដើម្បីទទួលបាននូវបទដ្ឋាន CCB សម្រាប់ជីវចម្រុះកម្រិតមាស សម្រាប់លក្ខណៈវិនិច្ឆ័យដូចខាងក្រោមនេះ:<br>ក. ភាពងាយរងគ្រោះ -ប្រភេទសត្វរងការគំរាមកំហែងចំនួនច្រើនជាង ៤០ បានបញ្ជាក់ថាប្រភេទសត្វដែលរងការគម្រាម កំហែងនៅទូទាំងពិភពលោកដែលមានវត្តមាននៅក្នុងតំបន់គម្រោង។<br>ខ. ការមិនអាចជំនួស - តំបន់គម្រោងមានចំនួនប្រភេទសត្វជាច្រើនយ៉ាងហោចណាស់ប្រភេទសត្វដែលដែនជម្រកមានកម្រិតចំនួនបីប្រភេទ និងចំនួនដ៏ច្រើននៃចំនួនសរុបលើពិភពលោកនៃប្រភេទសត្វចំនួនប្រាំផ្សេងទៀត។ |
| កម្រិតមាស<br><br>(Gold Level) | កម្រិតមាសត្រូវបានផ្តល់ឱ្យសម្រាប់ផលប្រយោជន៍ជីវៈចម្រុះដ៏ប្រសើរ ដោយផ្អែកលើសូចនករនៃ ភាពរងគ្រោះ នៅពេលដែលគម្រោងផ្តល់នូវផលវិជ្ជមានដ៏សំខាន់ ទៅលើតំបន់ដែលមានគុណតម្លៃសម្រាប់ការអភិរក្ស ដែលរួមបញ្ចូលនូវប្រភេទដែលងាយរងគ្រោះជាលក្ខណៈសាកល។ |
| រៀបរៀងដោយ | **អង្គការសមាគមអភិរក្សសត្វព្រៃតំណាងឱ្យក្រសួងបរិស្ថាននៃរាជរដ្ឋាភិបាលកម្ពុជា** |
| ទំនាក់ទំនង | **ក្រសួងបរិស្ថាន៖ ឯកឧត្តម បណ្ឌិត ជួប បារីស** *(*H.E. Dr. Paris Choup) **ក្រុមប្រឹក្សាជាតិ អភិវឌ្ឍន៍ដោយចីរភាព** paris.ncgg@gmail.com, www.moe.gov.kh<br>**អង្គការសមាគមអភិរក្សត្វព្រៃ៖បណ្ឌិត កែន សេរីរដ្ឋា** (Dr. Sereyrotha Ken) sken@wcs.org www.wcscambodia.org |

# មាតិការ

ការសង្ខេបស្តីពីផលប្រយោជន៍គម្រោងរេដបូកកែវសីមា ..... iv
តារាងម៉ាទ្រិចស្តង់ដារស្តីពីផលប្រយោជន៍គម្រោងរេដបូកកែវសីមា..... iv
១ ទិដ្ឋភាពទូទៅ ..... 10
១.១ សេចក្តីបរិយាយសង្ខេបអំពីគម្រោង (G៣) ..... 10
១.២ ទីតាំងគម្រោង ..... 13
១.៣ ម្ចាស់គម្រោង (G៤)..... 15
១.៤ អង្គភាពដទៃទៀតដែលចូលរួមក្នុងគម្រោងនេះ (G៤)..... 16
២. ការតាមដាន និងអនុវត្តគម្រោង ..... 18
២.១. កិច្ចអន្តរាគមន៍ដោយផ្ទាល់ ..... 18
២.២.កិច្ចអន្តរាគមន៍គាំទ្រ ..... 30
៣. ស្ថានភាពផ្នែកច្បាប់ ..... 34
៣.១. ការអនុលោមទៅតាមច្បាប់ និង សិទ្ធិកាន់កាប់ដីធ្លី..... 34

## ការសង្ខេបស្តីពីផលប្រយោជន៍គម្រោងរេដបូកកែវសីមា

| លទ្ធផលគម្រោង | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលតាមដានគម្រោង | ផ្នែកនៃឯកសាយោង | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលអនុវត្តគម្រោងទាំងមូល |
|---|---|---|---|
| ចំនួននៃការចុះបញ្ជីសមូហភាពសហគមន៍ជនជាតិដើមភាគតិចជាផ្លូវការនៅក្នុងតំបន់គម្រោង | ចំនួននៃការចុះបញ្ជីសមូហភាពសហគមន៍ជនជាតិដើមភាគតិចចំនួន ៣ ស្ថិតនៅក្នុងដំណើរការ | ២ | សហគមន៍ជនជាតិដើមភាគតិចចំនួន ៣ នៃសហគមន៍ទាំង ១៤ ទទួលបានប័ណ្ណកម្មសិទ្ធិ |

តារាងម៉ាទ្រិចស្តង់ដារស្តីពីផលប្រយោជន៍គម្រោងរេដបូកកែវសីមា

| ប្រភេទចំណាត់ថ្នាក់ | ម៉ាទ្រិច | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលតាមដានគម្រោង | ផ្នែកនៃឯកសាយោង | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលអនុវត្តគម្រោងទាំងមូល |
|---|---|---|---|---|
| ការកាត់បន្ថយការបំភាយ និងស្រូបយកចេញឧស្ម័នផ្ទះកញ្ចក់ | ការកាត់បន្ថយការបំភាយឧស្ម័នតាមរយៈការស្រូបយកចេញដែលបានប៉ាន់ស្មាននៅក្នុងតំបន់គម្រោងដែលវាស់វែងជាមួយសេណារីយ៉ូដែលគ្មានវត្តមានគម្រោង | មិនមាន | មិនមាន | មិនមាន |
| | ការកាត់បន្ថយការបំភាយឧស្ម័នដែលបានប៉ាន់ស្មាននៅក្នុងតំបន់គម្រោងដែលវាស់វែងជាមួយសេណារីយ៉ូដែលគ្មានវត្តមានគម្រោង | 4,523,996 | 3.2 | 14,781,256 |

| ប្រភេទចំណាត់ថ្នាក់ | ម៉ាទ្រិច | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលតាមដានគម្រោង | ផ្នែកនៃឯកសាយោង | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលអនុវត្តគម្រោងទាំងមូល |
|---|---|---|---|---|
| គម្របព្រៃឈើ[1] | សម្រាប់គម្រោងរេដបូក[2]: ចំនួនហិកតានៃការបាត់បង់ព្រៃឈើនៅក្នុងតំបន់គម្រោងត្រូវបានវាស់វែងដោយធៀបទៅនឹងសេណារីយ៉ូដែលគ្មានគម្រោង | 5,325 | 3.2 | 17,849 |
| | សម្រាប់ការដាំដុះព្រៃឈើ ការដាំព្រៃឈើឡើងវិញ និងការបង្កើនដំណុះរុក្ខជាតិឡើងវិញ[3] : ចំនួនហិកតានៃគម្របព្រៃឈើដែលកើនឡើងនៅក្នុងតំបន់គម្រោង ត្រូវបានវាស់វែងដោយធៀបទៅនឹងសេណារីយ៉ូដែលគ្មានគម្រោង | មិនមាន | មិនមាន | មិនមាន |
| ការធ្វើអោយប្រសើរឡើងនូវការគ្រប់គ្រងដីធ្លី | ចំនួនហិកតានៃដីព្រៃផ្តល់ផល ដែលមានស្រាប់ដែលការអនុវត្ត ការកែលម្អការគ្រប់គ្រងព្រៃឈើ (IFM)[4] បានធ្វើឡើងដោយសារលទ្ធផលនៃសកម្មភាពរបស់គម្រោងដែលបានវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង | មិនមាន | មិនមាន | មិនមាន |

[1] ដីធ្លីជាមួយបន្លែដុះដាលនូវរុក្ខជាតិ ដែលមាននិយមន័យទទួលស្គាល់ជាអន្តរជាតិ (ដូចជា UNFCCC, FAO ឬ IPCC) នៃអ្វីដែលបង្កើតជាព្រៃដែលរួមបញ្ចូលប៉ារ៉ាម៉ែត្រដែលមានកំរិតដូចជា ព្រៃឈើអប្បបរមាកម្ពស់ដើមឈើនិងកម្រិតនៃគម្របកន្សោមស្លឹក ហើយអាចរួមបញ្ចូលទាំងព្រៃចាស់ៗ ព្រៃដុះលូតលាស់ឡើងវិញ ព្រៃរេចរិលនិងព្រៃតំបន់ដីសើម (និយមន័យកម្មវិធី VCS) ។

[2] កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ចេញពីការបាត់បង់ព្រៃឈើនិងរិចរិលព្រៃឈើ (REDD): សកម្មភាពដែលកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ (GHG) ដោយកាត់បន្ថយឬបញ្ឈប់ការបំលែង ពីដីព្រៃឈើទៅជាដីដែលមិនមែនជាព្រៃឈើឬកាត់បន្ថយការរិចរិលនៃដីព្រៃដែលជីវម៉ាស់ព្រៃឈើត្រូវបានបាត់បង់ (និយមន័យកម្មវិធី VCS) ។

[3] ការដាំដុះព្រៃឈើ ការដាំព្រៃឈើឡើងវិញ និងការបង្កើនដំណុះរុក្ខជាតិឡើងវិញ (ARR): សកម្មភាពដែលបង្កើនបរិមាណកាបូននៅក្នុងជីវម៉ាស់ឈើ (និងដីខ្លះ) តាមរយៈការបង្កើត ការបង្កើន និង / ឬការស្តារគម្របរុក្ខជាតិលូតលាស់ឡើងវិញតាមរយៈការដាំដុះ ការសាបនិង / ឬការបង្កើតឡើងវិញដោយដំណុះជាធម្មជាតិតាមការជួយរបស់មនុស្ស (និយមន័យកម្មវិធី VCS) ។

[4] ការកែលម្អការគ្រប់គ្រងព្រៃឈើ (IFM): សកម្មភាពដែលផ្លាស់ប្តូរទំលាប់នៃការគ្រប់គ្រងព្រៃឈើ និងបង្កើនកាបូនលើដីព្រៃឈើសម្រាប់ផលិតផលឈើដូចជាឈើអា ឈើគៀប និងអុសដុត (និយមន័យកម្មវិធី VCS) ។

| ប្រភេទចំណាត់ថ្នាក់ | ម៉ាទ្រិច | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលតាមដានគម្រោង | ផ្នែកនៃឯកសាយោង | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលអនុវត្តគម្រោងទាំងមូល |
| --- | --- | --- | --- | --- |
| | ចំនួនហិកតាដីមិនមែនព្រៃ ដែលត្រូវបានគ្រប់គ្រងដោយប្រសើរឡើង ជាលទ្ធផលកើតឡើងដោយសារសកម្មភាពរបស់គម្រោងដែលបានវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង | មិនមាន | មិនមាន | មិនមាន |
| ការបណ្តុះបណ្តាល | ចំនួនសមាជិកសហគមន៍សរុបដែលបានបង្កើនជំនាញនិង / ឬចំណេះដឹងដែលជាលទ្ធផលនៃការបណ្តុះបណ្តាលដែលបានផ្តល់ដែលជាផ្នែកមួយនៃសកម្មភាពគម្រោង | 3,706 | 2 | 12,793 |
| | ចំនួនសមាជិកសហគមន៍ដែលជាស្ត្រីបានបង្កើនជំនាញនិង / ឬចំណេះដឹងដែលជាលទ្ធផលនៃការបណ្តុះបណ្តាលដែលបានផ្តល់ជាផ្នែកមួយនៃសកម្មភាពគម្រោង | 1,251 | 2 | 4,114 |
| ការងារ | ចំនួនសរុបនៃមនុស្សដែលបានធ្វើការក្នុងសកម្មភាពគម្រោង [5] ដែលសំដៅទៅលើចំនួនបុគ្គលិកពេញម៉ោង[6] | 160 | 2 | 1,280 |

[5] ការងារនៅក្នុងសកម្មភាពគម្រោងមានន័យថាជាអ្នកធ្វើការងារដោយផ្ទាល់លើសកម្មភាពរបស់គម្រោងដើម្បីទទួលបានប្រាក់សំណង (ហិរញ្ញវត្ថុ ឬ អ្វីៗផ្សេងទៀត) រួមទាំងបុគ្គលិក បុគ្គលិកដែលជាប់កិច្ចសន្យា កម្មករដែលបានចុះកិច្ចសន្យានិងសមាជិកសហគមន៍ដែលទទួលបានប្រាក់កម្រៃ ដើម្បីធ្វើការងារពាក់ព័ន្ធនឹងគម្រោង។

[6] ភាពសមមូលការងារពេញម៉ោងត្រូវបានគេគណនាជាចំនួនសរុបនៃម៉ោងធ្វើការ (ដោយបុគ្គលិកពេញម៉ោង ក្រៅម៉ោង បណ្តោះអាសន្ននិង / ឬតាមរដូវកាល) ដោយចែកដោយចំនួនម៉ោងធ្វើការមធ្យមនៅក្នុងការងារពេញម៉ោងនៅក្នុងប្រទេស និងតំបន់ឬតំបន់សេដ្ឋកិច្ច (អនុលោមទៅតាមប្រព័ន្ធគណនេយ្យរបស់អង្គការសហប្រជាជាតិ (1993) វគ្គ 17.14 [15.102] [17.28]) ។

| ប្រភេទចំណាត់ថ្នាក់ | ម៉ាទ្រិច | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលតាមដានគម្រោង | ផ្នែកនៃឯកសាយោង | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលអនុវត្តគម្រោងទាំងមូល |
|---|---|---|---|---|
| | ចំនួនស្ត្រីដែលបានធ្វើការក្នុងសកម្មភាពគម្រោង ដែលសំដៅទៅលើចំនួនបុគ្គលិកពេញម៉ោង | 17 | 2 | 136 |
| ការបង្កើនជីវភាព | ចំនួនប្រជាពលរដ្ឋសរុបដែលមានជីវភាព [7] ប្រសើរជាងមុនឬចំណូលដែលបានមកពីសកម្មភាពគម្រោង | 927 | 2, 4 | 4,712 |
| | ចំនួនស្ត្រីដែលមានជីវភាពប្រសើរឡើងឬទទួលបានប្រាក់ចំណូលដែលបានមកពីការធ្វើសកម្មភាពរបស់គម្រោង | 125 | 2, 4 | 1,626 |
| សុខភាព | ចំនួនប្រជាពលរដ្ឋដែលបានទទួលសេវាសុខភាពប្រសើរជាងមុនដោយសារសកម្មភាពរបស់គម្រោងដែលបានត្រូវបានវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង | 2,765 | 2 | 2,825 |
| | ចំនួនស្ត្រីដែលបានទទួលសេវាសុខភាពប្រសើរជាងមុនដោយសារសកម្មភាពរបស់គម្រោងដែលបានវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង | 752 | 2 | 772 |
| ការអប់រំ | ចំនួនសរុបនៃមនុស្សដែលទទួលបានការអប់រំឬគុណភាពនៃការអប់រំត្រូវ | 22 | 4 | 165 |

[7] ជីវភាពរស់នៅគឺជាសមត្ថភាព ទ្រព្យសម្បត្តិ (រួមទាំងទ្រព្យសម្បត្តិនិងធនធានសង្គម) និងសកម្មភាពចាំបាច់សម្រាប់ការរស់ (Krantz, Lasse, 2001. *The Sustainable Livelihood Approach to Poverty Reduction*. SIDA) អត្ថប្រយោជន៍នៃការប្រកបមុខរបរអាចរាប់បញ្ចូលទាំងអត្ថប្រយោជន៍ដែលបានរាយការណ៍នៅក្នុងតារាងម៉ែត្រការងារនៃតារាងនេះ។

| ប្រភេទចំណាត់ថ្នាក់ | ម៉ាទ្រិច | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលតាមដានគម្រោង | ផ្នែកនៃឯកសារយោង | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលអនុវត្តគម្រោងទាំងមូល |
|---|---|---|---|---|
| | បានកែលម្អជាលទ្ធផលនៃសកម្មភាពគម្រោងដែលត្រូវបានវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង | | | |
| | ចំនួនស្ត្រីនិងក្មេងស្រីដែលទទួលបានគុណភាពអប់រំដែលត្រូវបានកែលម្អដោយសារលទ្ធផលនៃគម្រោងដែលត្រូវបានវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង | 7 | 4 | 78 |
| ទឹក | ចំនួនមនុស្សសរុបដែលទទួលបានការបង្កើនគុណភាពទឹកនិង / ឬបង្កើនលទ្ធភាពទទួលបានទឹកបរិភោគជាលទ្ធផលនៃសកម្មភាពគម្រោងដែលត្រូវបានវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង។ | 2,096 | 4 | 2,812 |
| | ចំនួនស្ត្រីដែលទទួលបានការបង្កើនគុណភាពទឹកនិង / ឬបង្កើនលទ្ធភាពទទួលបានទឹកផឹកដែលជាលទ្ធផលនៃសកម្មភាពគម្រោងដែលវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង | 760 | 4 | 1,103 |
| សុខុមាលភាព | ចំនួនសមាជិកសហគមន៍សរុបដែលសុខុមាលភាព [8] ត្រូវបានកែលម្អដែល | 3,247 | 4 | 8,399 |

[8] សុខុមាលភាពគឺជាបទពិសោធរបស់ប្រជាជនអំពីគុណភាពនៃជីវិតរបស់ពួកគេ។ ផលប្រយោជន៍ខាងសុខមាលភាពអាចរាប់បញ្ចូលផលប្រយោជន៍ដែលបានរាយការណ៍នៅក្នុងតារាងដទៃទៀតនៃតារាងនេះ (ឧ. ការបណ្តុះបណ្តាល ការងារ សុខាភាព អប់រំ ទឹកស្អាតជាដើម) ប៉ុន្តែក៏អាចរួមបញ្ចូលផលប្រយោជន៍ផ្សេងទៀតដូចជា ការផ្តល់សិទ្ធិអំណាចដល់ក្រុមសហគមន៍ ពង្រឹងសិទ្ធិស្របច្បាប់ទៅលើធនធាន, ការអភិរក្សការប្រើប្រាស់នូវតំបន់ដែលមានសំខាន់សម្រាប់វប្បធម៌ ។ល។

| ប្រភេទចំណាត់ថ្នាក់ | ម៉ាទ្រិច | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលតាមដានគម្រោង | ផ្នែកនៃឯកសាយោង | សមិទ្ធិផលសម្រេចបានក្នុងកំឡុងពេលអនុវត្តគម្រោងទាំងមូល |
|---|---|---|---|---|
| | ជាលទ្ធផលនៃសកម្មភាពរបស់គម្រោង | | | |
| | ចំនួនស្ត្រីដែលសុខុមាលភាពរបស់ពួកគេត្រូវបានកែលម្អជាលទ្ធផលនៃសកម្មភាពរបស់គម្រោង | 1,622 | 4 | 4,162 |
| ការអភិរក្សជីវៈចម្រុះ | ការផ្លាស់ប្តូរចំនួនហិកតាដែលគ្រប់គ្រងបានល្អប្រសើរដោយគម្រោងសម្រាប់ការអភិរក្សជីវចំរុះ [9] ដែលវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង | 187,983 ha | 5.1 | 187,983 ha |
| | ចំនួននៃប្រភេទសត្វដែលជិតផុតពូជឬងាយរងគ្រោះ [10] ដែលត្រូវបានទទួលផលប្រយោជន៍ពីការកាត់បន្ថយការគំរាមកំហែងដែលជាលទ្ធផលនៃសកម្មភាពគម្រោង [11] ដែលវាស់វែងជាមួយសេណារីយ៉ូគ្មានគម្រោង | ប្រភេទសត្វដែលជិតផុតពូជ: 8 ប្រភេទងាយរងគ្រោះ: 21 | 5.1 | ប្រភេទសត្វដែលជិតផុតពូជ: 8 ប្រភេទងាយរងគ្រោះ: 21 |

[9] ការអភិរក្សជីវចម្រុះនៅក្នុងបរិបទនេះមានន័យថាជាតំបន់ ដែលវិធានការគ្រប់គ្រងជាក់លាក់ត្រូវបានអនុវត្តជាផ្នែកមួយនៃសកម្មភាពគម្រោងដែលមានគោលបំណងលើកកំពស់ការអភិរក្សជីវចម្រុះ។

[10] យោងទៅតាមបញ្ជីក្រហម IUCN នៃប្រភេទដែលត្រូវបានគំរាមកំហែងដោយ ។

[11] ដោយមិនមានវត្តមាននូវការវាស់វែងនូវចំនួន និងវត្តមានរបស់ប្រភេទ រាល់ការវាស់វែងនូវ ការកាត់បន្ថយការគំរាមកំហែងត្រូវបានគេប្រើជាភស្តុតាងនៃផលប្រយោជន៍សម្រាប់ការអភិរក្ស។

# ១ ទិដ្ឋភាពទូទៅ

## ១.១ សេចក្តីបរិយាយសង្ខេបអំពីគម្រោង (G៣)

តំបន់ដែនជម្រកសត្វព្រៃកែវសីមា គ្របដណ្តប់លើផ្ទៃដីទំហំ ២៩២ ៦៩០ហិកតា។ តំបន់នេះ ស្ថិតនៅភាគខាងកើតប្រទេសកម្ពុជា ដែលភាគច្រើនស្ថិតក្នុងខេត្ត មណ្ឌលគិរី និង មានមួយផ្នែកតូច ស្ថិតក្នុងខេត្តក្រចេះ។ គម្រោងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ដែលបណ្តាលមកពីការបាត់បង់ព្រៃឈើ និង ការរេចរិលនៃព្រៃឈើ (**REDD+**) គ្របដណ្តប់លើផ្ទៃដីព្រៃទំហំ ១៦៦ ៩៨៣ ហិកតា ដែលស្ថិត នៅក្នុងតំបន់ការពារស្នូលរបស់ តំបន់ដែនជម្រកសត្វព្រៃកែវសីមា។ នៅចុងឆ្នាំ២០០៩ តំបន់ការពារ នេះ ត្រូវបានបង្កើតឡើង ដោយអនុក្រឹត្យ របស់នាយករដ្ឋមន្ត្រី ជា"តំបន់ព្រៃការពារសីមា"។ ដំណើរ ការនេះ បានលើកកម្ពស់ ស្ថានភាពអភិរក្សអតីតតំបន់អភិរក្សជីវចម្រុះសីមា ដែលបានដំណើរការនៅ ក្នុងអំឡុងឆ្នាំ ២០០២-២០០៩។ មកដល់ឆ្នាំ ២០១៦ តំបន់ព្រៃការពារសីមា ត្រូវបាន ចាត់ថ្នាក់ ឡើងវិញ ដោយរាជរដ្ឋាភិបាលកម្ពុជាជា"តំបន់ដែនជម្រកសត្វព្រៃ កែវសីមា" ក្រោមអនុក្រឹត្យលេខ ៨៣ ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១៦ និងស្ថិតក្នុងការ គ្រប់គ្រងរបស់ក្រសួងបរិស្ថាន។ ទីតាំងនេះ គឺជាផ្នែកមួយនៃទឹកដីកំណើតតាំងពីដូនតារបស់ជនជាតិ ដើមភាគតិចព្នងយ៉ាងច្រើន ហើយសម្រាប់ ពួកគាត់ ព្រៃឈើ គឺជាប្រភពប្រាក់ចំណូលដ៏សំខាន់ និងជាស្នូល នៃជំនឿរបស់ពួកគាត់ទៅលើព្រលឹង។ មិនតែប៉ុណ្ណោះ តំបន់នេះ គឺជាទីប្រជុំតំបន់បរិស្ថាន ដ៏សំខាន់ចំនួនពីរពោលគឺជួរភ្នំអាណាម (ដែលគួរឱ្យកត់សម្គាល់ទៅលើលក្ខណៈខុសប្លែកពីគេយ៉ាងខ្លាំងនៅមូលដ្ឋាន ក្នុងចំណោមប្រភេទ ព្រៃស្រោង រឺ បៃតងគ្រប់រដូវកាល) និងព្រៃ ល្បោះស្ងួតនៅតំបន់ទន្លេមេគង្គក្រោម (ដែលមានសារ សំខាន់បំផុតសម្រាប់ការរស់រាន របស់រុក្ខជាតិជាច្រើនប្រភេទដែលមានលក្ខណៈជា ព្រៃជ្រុះស្លឹក ប្រចាំឆ្នាំនៅតាមតំបន់ដីទំនាប)។ មានសត្វមានឆ្អឹងខ្នងចំនួន ៤១ប្រភេទ ដែលទទួលរងការគម្រាម កំហែងទូទាំងសាកលលោក ដែលត្រូវបានរកឃើញនៅក្នុងតំបន់គម្រោងនេះ (ក្នុងនោះ ៤ប្រភេទ ប្រឈមនឹងការផុតពូជខ្លាំងបំផុត និង១៤ប្រភេទប្រឈមនឹងការផុតពូជ)។ ភាគច្រើននៃប្រភេទ សត្វ ទាំងនេះស្ថិតក្នុងចំនួនមួយដែលត្រូវយកចិត្តទុកដាក់ជាសាកល ឬ នៅថ្នាក់តំបន់ដែល រួមមានដំរី អាស៊ី អម្បូរស្វា អម្បូរគោព្រៃ អម្បូរមំសាសី និង បក្សី ដូចជា ត្រយ៉ងយក្ស និង ក្ងោក។

ក្នុងពេលបច្ចុប្បន្ននេះតំបន់ដែនជម្រកសត្វព្រៃកែវសីមា ស្ថិតក្រោមការគំរាមកំហែងពីការកើន ឡើងនូវការកាប់រាន ព្រៃសម្រាប់ធ្វើកសិកម្មស្របគ្នានឹងការទាញយកធនធាន ដែលគ្មាន និរន្តរភាព (ដូចជា ការបរបាញ់សត្វ ការកាប់ឈើ និង ការធ្វើនេសាទ)។ សកម្មភាពទាំង នេះធ្វើឱ្យប៉ះពាល់ ទាំង ទៅលើជីវចម្រុះ និងការប្រកបរបរចិញ្ចឹមជីវិតដែល ពឹងផ្អែកទៅលើ ព្រៃឈើក្នុងមូលដ្ឋាន។ កត្តា ជំរុញការគម្រាមកំហែងដោយផ្ទាល់ក្នុងពេលបច្ចុប្បន្ននេះមានដូចជា កំណើននៃការប្រើប្រាស់ផ្លូវថ្នល់ កំណើនប្រជាជនក្របខ័ណ្ឌអនុវត្តច្បាប់ និង អភិបាលកិច្ចមានភាពទន់ខ្សោយ ការមិនសូវយល់ដឹងពី

គុណតម្លៃរបស់ជីវចម្រុះ សេវាកម្មផ្នែកបរិស្ថាន និង កំណើនតម្រូវការទីផ្សារ ទាំងទៅលើផលិតផលពីព្រៃ និង ផលិតផលកសិកម្ម។ ការអភិវឌ្ឍធនធានរ៉ែ និងដំណាំកសិឧស្សាហកម្មក៏អាចក្លាយជាកត្តាបំផ្លិចបំផ្លាញព្រៃឈើក្នុងពេលអនាគតដ៏មានសក្តានុពលផងដែរ ប្រសិនបើរដ្ឋាភិបាលមិនបានការពារតំបន់នោះយ៉ាងពេញលេញទេ។ ការប្រមូលផលប្រភេទឈើប្រណិតកម្រដោយខុសច្បាប់គឺទាក់ទងនឹងកិច្ចការអនុវត្តច្បាប់ដ៏តឹងរឹងនៅក្នុងទីតាំងនោះ ក៏ដូចជានៅតាមកន្លែងផ្សេងទៀតនៅក្នុងប្រទេសកម្ពុជាដែរ ក៏ប៉ុន្តែវាមានឥទ្ធិពលតិចតួច ក្នុងរយៈពេលវែងទៅលើការស្តុកទុកកាបូន។

ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋបាលព្រៃឈើបានសហការជាមួយនឹងអង្គការអភិរក្សសត្វព្រៃ (WCS) និងដៃគូអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយចំនួនទៀតដើម្បីបង្កើតប្រព័ន្ធគ្រប់គ្រងតំបន់ដែនជម្រកសត្វព្រៃកែវសីមា សម្រាប់ថែរក្សា និងស្តារតម្លៃជីវចម្រុះ ព្រមទាំង ការពារមុខរបររបស់ប្រជាជនមូលដ្ឋានផងដែរ។ គម្រោងអភិរក្សនេះមានវិធីសាស្ត្រ គ្រប់ជ្រុងជ្រោយមួយ ដែលមានអន្តរាគមន៍ផ្ទាល់ចំនួន៤៖ ការពង្រឹងយន្តការច្បាប់ និង ការគាំទ្រផ្នែកគោលនយោបាយ ការអនុវត្តច្បាប់ដោយផ្ទាល់ការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិក្នុងសហគមន៍ និងការបង្កើតមុខរបរជំនួស។ ការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាពមានសារសំខាន់ខ្លាំងណាស់ ព្រោះវាជួយគាំទ្រដល់គ្រប់សកម្មភាពការងារផ្សេងទៀត ។ ការរួមចំណែកប្រកបដោយនិរន្តរភាពក្នុងការគាំទ្រដល់ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីសមូហភាពជូនសហគមន៍ជនជាតិដើមភាគតិចទាំងអស់នៅក្នុងតំបន់នោះ មានលក្ខណៈគួរឱ្យ កត់ សម្គាល់បំផុត ពីព្រោះវាការពារមុខរបរ និង សិទ្ធិកាន់កាប់ដីធ្លីរបស់ពួកគាត់ ហើយទន្ទឹមគ្នានោះបង្កើតបានជាមូលដ្ឋានរឹងមាំមួយសម្រាប់សហការគ្នាអនុវត្តគម្រោងនេះ។

នៅក្នុងឆ្នាំ២០១៦ តំបន់ដែនជម្រកសត្វព្រៃកែវសីមា ត្រូវបានផ្ទេរទៅអោយក្រសួងបរិស្ថានជាអ្នកគ្រប់គ្រង ដែលជាផ្នែកមួយនៃការផ្ទេរដែនសមត្ថកិច្ចគ្រប់គ្រងថ្នាក់ជាតិ នៃតំបន់ការពារទាំងអស់ទៅអោយក្រសួងបរិស្ថានជាអ្នកគ្រប់គ្រង។ ក្នុងខណៈពេលនោះ ដែរ ក្រសួងបរិស្ថានក៏បានផ្លាស់ប្តូរឈ្មោះ ព្រៃការពារសីមា ទៅជាតំបន់ដែនជម្រកសត្វព្រៃកែវសីមា និងទទួលខុសត្រូវលើការអនុវត្តតំបន់គម្រោង និងការអនុវត្តសកម្មភាពរេដបូក។ បុគ្គលិកភាគច្រើនត្រូវបានរក្សានូវដដែល និងប្តូរទៅក្រសួងបរិស្ថានដោយរក្សានូវតួនាទី និង ភារកិច្ចនៅដដែរ។ អង្គការ WCS ជាដៃគូរអភិវឌ្ឍន៍ជាមួយក្រសួងបរិស្ថានតាំងពីឆ្នាំ ២០០០ តាមរយៈសហគ្រប់គ្រងតំបន់ការពារ នៃគម្រោងការអភិរក្សព្រៃកទាល់ និង តំបន់ដែន ជម្រកសត្វព្រៃ គូលែនព្រហ្មទេព។

ការអន្តរាគមដើម្បីអភិរក្សនៅមុនពេលអនុវត្តគម្រោងរេដ គឺនៅមានកម្រិតតិចតួចនៅ ឡើយ។ សកម្មភាពអនុវត្តច្បាប់ទទួលបានជោគជ័យក្នុងការកាត់បន្ថយ (ក៏ប៉ុន្តែមិនបានទប់ស្កាត់) ការគម្រាមកំហែងធំៗនៅគ្រប់ផ្នែករបស់តំបន់ដែនជម្រកសត្វព្រៃកែសីមា ដោយបានកាត់បន្ថយអត្រាកាប់បំផ្លាញព្រៃឈើ និង បានជួយឱ្យប្រភេទសត្វព្រៃសំខាន់ៗមួយចំនួននៅគង់វង្សក្នុងចំនួនច្រើន។ ការអន្តរាគមក្នុងកម្រិតតិចតួចនេះត្រូវបានសន្និដ្ឋានថានឹងបន្ត ធ្វើជាផ្នែកមួយនៃគម្រោងមូលដ្ឋានក្នុង

ពេលអនាគត។ ទោះបីជាបែបណាក្តី អន្តរាគមន៍នេះស្ថិតនៅក្រោមកម្រិតមួយដែលចង់បាន ដើម្បីឆ្លើយតបទៅនឹងទ្រង់ទ្រាយនៃការគម្រាមកំហែងទាំងឡាយ។ ការគម្រាមកំហែងភាគច្រើននៅតែមានកម្រិតធ្ងន់ធ្ងរនៅឡើយ ហើយកំពុងបន្តកើនឡើងទាំងទ្រង់ទ្រាយ និង ប្រភេទខុសៗគ្នា។ អត្រាកាប់ឈើ និង កាប់បំផ្លាញព្រៃឈើបានកើនឡើង ដោយក្នុងនោះយ៉ាងហោចណាស់មានសត្វដ៏សំខាន់មួយប្រភេទ (ខ្លា) បានធ្វើឱ្យបាត់បង់ពីចំនួនដែលបម្រុងទុក ហើយរំពឹងថានឹងមានការថយចុះបែបនេះសម្រាប់ ប្រភេទសត្វដទៃទៀត។ ការកំណត់ព្រំប្រទល់ ការយាមល្បាតប្រកបដោយប្រសិទ្ធភាព ការចុះអប់រំតាមសហគមន៍ សកម្មភាពប្រកបមុខរបរផ្សេងពីមុន ជាដើម ត្រូវបានអនុវត្តតែ ទៅលើមួយផ្នែកធំនៃព្រៃបម្រុងនោះប៉ុណ្ណោះ។ ប្រសិទ្ធភាពក្នុងការគ្រប់គ្រង ការអភិរក្ស ត្រូវបានរារាំងយ៉ាងខ្លាំង ដោយសារតែ ការផ្តល់មូលនិធិមិនបានគ្រប់គ្រាន់ មិនទៀងទាត់ និង បន្តធ្លាក់ចុះ ព្រមគ្នាជាមួយនឹងការដណ្តើមប្រើប្រាស់ដីធ្លី។ ហេតុដូច្នេះ ហើយការផ្តល់ហិរញ្ញប្បទានប្រកបដោយនិរន្តរភាពតាមរយៈប្រាក់ចំណូលពីការលក់កាបូន មានសារសំខាន់ណាស់សម្រាប់សម្រួលដល់ការពង្រីក និង ការទ្រទ្រង់សកម្មភាពអភិរក្សសម្រាប់រយៈពេលវែង។ កត្តានេះនឹងជួយដល់រាជរដ្ឋាភិបាលកម្ពុជា និង ដៃគូអង្គការមិនមែនរដ្ឋាភិបាលរបស់ខ្លួនក្នុងការពង្រីកសកម្មភាពបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងកម្រិតនៃការគំរាមកំហែងធានាការគាំទ្រសម្រាប់រយៈពេលវែងតាមរយៈការរ៉ាប់រងលើការចំណាយប្រតិបត្តិការ និង ផ្តល់រង្វាន់លើកទឹកចិត្តជាថវិកាសម្រាប់ការអភិរក្សនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ។

គម្រោងនេះទទួលបានប្រយោជន៍ពីការគាំទ្រដ៏ខ្លាំងក្លា និងប្រកបដោយនិរន្តរភាពពីម្ចាស់ជំនួយ និង ផ្នែកនយោបាយ ដៃគូអង្គការមិនមែនរដ្ឋាភិបាលដែលមានទស្សនៈ បើកចំហ រួមសហការ មានស្ថេរភាព និង មានរយៈពេលវែង វត្តមានបុគ្គលកាន់មុខតំណែងជា អ្នកដឹកនាំដែលមានការប្តេជ្ញាចិត្តខ្ពស់ ការទទួលស្គាល់ថា ការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព និង សមធម៌ គឺជាមូលដ្ឋានគ្រឹះសម្រាប់រាល់អន្តរាគមន៍ផ្សេងទៀត និង ឆន្ទៈក្នុងការអនុវត្តបច្ចេកទេសថ្មីៗ។ ការអនុវត្តសាកល្បងនូវបច្ចេកទេសមួយចំនួនចាប់តាំងពីឆ្នាំ២០០២មក កំណត់បាននូវវិធីសាស្ត្រជោគជ័យមួយចំនួនក្នុងការដោះស្រាយបញ្ហាប្រឈមសំខាន់ៗមួយចំនួនធំដែលបានជួបប្រទះហើយបូករួមនឹងហិរញ្ញប្បទានគ្រប់គ្រាន់ ការគ្រប់គ្រងដ៏ពេញលេញ និង មានប្រសិទ្ធភាពអាចដំណើរការទៅបាន។

ការបរិយាយជាលម្អិតអំពីគោលដៅ និងសកម្មភាពដែលបានអនុវត្តកន្លងចាប់ពីឆ្នាំ ២០១០ ដល់ ២០១៥ មករបស់គម្រោងនេះ នឹងត្រូវបានបរិយាយនៅក្នុងរបាយការណ៍។

គម្រោងនេះមានគោលបំណងសម្រេចបាននូវការផ្តល់សុពលភាពរួមធៀបទៅនឹង ប្រព័ន្ធ ផ្តល់វិញ្ញាបនបត្របញ្ជាក់កាបូន (VCS) និង បទដ្ឋានសម្ព័ន្ធអាកាសធាតុ សហគមន៍ និង ជីវចម្រុះ (CCBA)។

## ១.២ ទីតាំងគម្រោង

គម្រោងនេះត្រូវបានធ្វើឡើងស្ទើរតែទាំងស្រុងនៅក្នុងដែនជម្រកសត្វព្រៃកែវសីមា ដែលភាគច្រើនស្ថិតនៅខេត្តមណ្ឌលគិរីដោយមានផ្នែកមួយចំនួនដែលលាតសន្ធឹងក្នុងខេត្តក្រចេះ។ តំបន់នេះមានព្រំប្រទល់ជាប់នឹងប្រទេសវៀតណាមដែលខណ្ឌចែកដោយផ្លូវជាតិលេខ ៧៦។ ទីស្នាក់ការកណ្តាលរបស់ដែនជម្រកសត្វព្រៃកែវសីមា ស្ថិតនៅភាគនិរតីនៅក្នុង ស្រុកកែវសីមានៅចំណុចលេខ 106 ◦ 55'15.7 "E, 12 ◦ 8'13.109" N ។

វិធីសាស្រ្តទាមទារនិយមន័យនៃតំបន់គ្រប់គ្រងដែលមិនត្រួតស៊ីគ្នាជាច្រើនដូចដែលបានរៀបរាប់លម្អិតនៅក្នុងផ្នែកទី 4.4 និងសង្ខេបនៅទីនេះ។ តំបន់គម្រោង (ដែលជាតំបន់ដែលឥណទាននឹងត្រូវបានបង្កើតឡើង) រួមមានផ្នែកទាំងនោះនៃតំបន់ព្រៃការពារស្នូល (ដូចបានកំណត់ក្នុងអនុក្រឹត្យលេខ ១៤៣ ឆ្នាំ ២០០៩) ដែលត្រូវបានគេទុកចោលនៅពេលកាលបរិច្ឆេទចាប់ផ្តើមគម្រោងដោយលើកលែងតែតំបន់ដែលត្រូវបានដកចេញដោយសារតែបញ្ហាពាក់ព័ន្ធនឹងការកាន់កាប់ដីធ្លីដ៏ស្មុគស្មាញ។ តំបន់លិចធ្លាយព័ទ្ធជុំវិញតំបន់ដែលនៅជាប់នឹងព្រៃឈើដែលគម្រោងនេះអាចប្រឈមនឹងបាត់បង់ព្រៃឈើមួយចំនួន។ តំបន់គ្រប់គ្រងតំបន់លិចធ្លាយជាតំបន់ដែលសកម្មភាពកែលម្អជីវភាពដែលត្រូវបានជ្រើសរើសនឹងមានដូចជា តំបន់មិនមែនព្រៃឈើ តំបន់កសិកម្មដែលត្រូវបានប្រើប្រាស់ដោយអ្នកភូមិដែលចូលរួមក្នុងគម្រោង។ រួមទាំងតំបន់ទាំងបីនេះគឺជាមូលដ្ឋាននៃតំបន់គម្រោងដែលត្រូវបានកំណត់តាមស្តង់ដារ CCB ។ រូបភាព 1.1 បង្ហាញពីទិដ្ឋភាពទូទៅនៃទីតាំងនៃតំបន់គម្រោង។ សម្រាប់ផែនទីលម្អិតនៃតំបន់ទាំងអស់សូមមើលផ្នែកទី 4 ។

រូបទី 1 **ផែនទីគម្រោងរេដបូកដែនជម្រកសត្វព្រៃកែវសីមា**




**ស្ថានភាពដី**(Topography)

ដែនជម្រកសត្វព្រៃកែវសីមា និងតំបន់ជុំវិញរបស់វាបង្កើតជាសណ្ឋានដីដែលមានសណ្ឋានដីចាប់ពី 60-750 ម៉ែត្រ។ ផ្នែកខាងក្រោមនៅភាគខាងជើង និងខាងលិចនៃតំបន់គម្រោងគឺស្ថិតនៅតំបន់វាលទំនាបភាគខាងកើត។ នៅខាងកើតតំបន់នេះបានកើនឡើងនៅលើកំពស់ទៅខ្ពង់រាបសែនមនោរម្យដែលបង្កើតជាតំបន់ភាគនិរតីនៃជួរភ្នំអាណាម ដែលជាចំណុចកណ្តាលមួយក្នុងចំណោមចំណុចកណ្តាលដ៏សម្បូរទៅដោយប្រភេទសត្វព្រៃនៃតំបន់អាស៊ី។

**ដី**

ដីមានបរិមាណដ៏មានសក្តានុពលខ្ពស់ទៅលើថ្មដែលចំណាស់ ជាលក្ខណៈខ្ពង់រាប ដែលដីទំនាបភាគច្រើនមានកម្រិតទាបទៅមធ្យម លើកលែងតែតំបន់ដីល្បប់នៅតំបន់មួយចំនួន។

**ជលសាស្ត្រ**

ដៃទន្លេទំហំមធ្យមពីរនៅតាមដងទន្លេមេគង្គបានបង្ហូរភាគច្រើននៃតំបន់នេះ ខណៈដែលជ្រលងភ្នំភាគខាងត្បូងលិចចូលក្នុងប្រព័ន្ធស្ទឹងដាយណៃ (Dai Nang) នៅវៀតណាម។ ទន្លេភាគច្រើនឈប់

ហូរក្នុងរដូវប្រាំងដែលមានរយៈភាពយូរ។ វាលទំនាបត្រូវបានសម្គាល់ដោយតំបន់ដីសើមតូចៗ សម្បូរទៅដោយស្មៅ និងត្រពាំងនៅតាមព្រៃ។

**អាកាសធាតុ**

អាកាសធាតុគឺតំបន់ត្រូពិចខ្យល់មូសុងៈ រដូវប្រាំងចាប់ពីខែវិច្ឆិកាដល់ខែមេសាជាមួយខ្យល់បក់ពីទិសខាងជើង និងរដូវវស្សាចាប់ពីខែឧសភាដល់ខែតុលាជាមួយខ្យល់បក់ពីខាងត្បូង ។ បរិមាណទឹកភ្លៀងប្រចាំឆ្នាំសរុបគឺ 2200-2800 មម នៅទីស្នាក់ការកណ្តាល ដែនជម្រកសត្វព្រៃកែវសីមា ជាចំនុចខ្ពស់ជាងគេនៅលើខ្ពង់រាប និងក៏ប្រហែលជាមានតំបន់ទំនាបទាបជាងគេផងដែរ ។ ភ្លៀងជាង 85% នៅទីស្នាក់ការកណ្តាលស្ថិតនៅក្នុងកំឡុងខែឧសភា - ខែតុលា។ ចាប់ពីខែធ្នូដល់ខែមេសាជាទូទៅមានកំពស់តិចជាង 100 មម ក្នុងមួយខែ ហើយតាមធម្មតារដូវប្រាំងមានរយៈពេល ៥ ខែ ។

## ១.៣ ម្ចាស់គម្រោង (G៤)

ម្ចាស់គម្រោងនេះ គឺរាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយ ក្រសួងបរិស្ថាន។ ក្រសួងបរិស្ថានទទួលខុសត្រូវក្នុងការគ្រប់គ្រងទីតាំងនេះ ដោយមានតួនាទីដូចខាងក្រោម ឬ សើលពីនេះ ៖

- ការចាត់តាំងបុគ្គលិក រួមមានប្រធានគ្រប់គ្រងតំបន់ការពារ ឬ អ្នកដែលមានតំណែងស្មើ
- ការបង្កើតផែនការងារ និង កញ្ចប់ថវិកា
- ការអនុវត្តសកម្មភាពទាំងឡាយ ដូចជា ការអនុវត្តច្បាប់ ការងារសហគមន៍ និង ការកំណត់ព្រំប្រទល់
- ការតាមដានមើលការចូលរួមរបស់ភ្នាក់ងារដទៃទៀតនៅក្នុងរដ្ឋាភិបាល ដូចជា កងកម្លាំងប្រដាប់អាវុធ ជាដើម
- ការសម្របសម្រួលជាមួយនឹងស្ថានប័នចំណុះរដ្ឋាភិបាល
- ការតាមដានមើលការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល

ពាក់ព័ន្ធនឹងគម្រោងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ដែលបណ្តាលមកពីការបាត់បង់ព្រៃឈើ និងការរេចរិលនៃព្រៃឈើក្រសួងបរិស្ថានទទួលខុសត្រូវដូចខាងក្រោម ៖

- ការត្រួតពិនិត្យ និង ការគ្រប់គ្រងជារួម (រួមទាំងក្របខ័ណ្ឌបែងចែកផលប្រយោជន៍ និងការសម្របសម្រួលដៃគូចូលរួមផងដែរ)
- ការចាត់តាំងបុគ្គលិកសំខាន់ៗ រួមមាន ប្រធានក្រុមការងារ និង អ្នកគ្រប់គ្រង
- ការអនុម័តទៅលើការអភិវឌ្ឍគម្រោងផែនការការងារ និង របាយការណ៍ត្រួតពិនិត្យ

- ការអនុវត្តសកម្មភាពមួយចំនួននៅក្នុងផែនការការងារដែលក្រសួងបរិស្ថានទទួលខុសត្រូវ
- ការសម្របសម្រួលការងាររបស់គម្រោងរេដពាក់ព័ន្ធនឹងទិដ្ឋភាពគ្រប់គ្រងតំបន់ដែនជម្រកសត្វព្រៃកែវសីមា

| ក្រសួងបរិស្ថាន នៃរាជរដ្ឋាភិបាលកម្ពុជា | |
|---|---|
| ទំនាក់ទំនង៖ | ឯឧត្តម បណ្ឌិត ជួប ប៉ារីស |
| តួនាទី៖ | អគ្គលេខាធិការរង នៃ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| អាស្រ័យដ្ឋាន៖ | ក្រសួងបរិស្ថាន រាជរដ្ឋាភិបាលកម្ពុជា<br># 48, វិថី សម្តេចព្រះសីហនុ ភ្នំពេញ 12301 កម្ពុជា |
| ទូរស័ព្ទ៖ | +855 23 213 908 |
| អ៊ីម៉ែល៖ | paris.ncgg@gmail.com |
| គេហទំព័រ៖ | www.moe.gov.kh |

## ១.៤ អង្គភាពដទៃទៀតដែលចូលរួមក្នុងគម្រោងនេះ (G៤)

អង្គការសមាគមអភិរក្សសត្វព្រៃ ដែលមានកម្មវិធីនៅក្នុងប្រទេសកម្ពុជា គឺជាដៃគូបច្ចេកទេសឈានមុខគេ។ អង្គការសមាគមអភិរក្សសត្វព្រៃបានសហការជាមួយនឹងរដ្ឋបាលព្រៃឈើនៅក្នុងទីតាំងនេះចាប់តាំងពីការស្ទង់មតិអំពីសត្វព្រៃលើកដំបូងក្នុងឆ្នាំ ២០០០ មកម្លេះ។ អង្គការសមាគមអភិរក្សសត្វព្រៃក៏បានសហការជាមួយក្រសួងបរិស្ថាន តាំងពីឆ្នាំ២០០០ តាមរយៈ សហគ្រប់គ្រងតំបន់ការពារ នៃគម្រោងការអភិរក្សព្រៃកទាល់ និង តំបន់ដែនជម្រកសត្វព្រៃ គូលែនព្រហ្មទេព។ អង្គការសមាគមអភិរក្សសត្វព្រៃធ្វើការ លើ គម្រោងរេដបូក ក្រោមអាណត្តិនៃកិច្ចព្រមព្រៀងបន្តគម្រោង ៣ ឆ្នាំម្តង ជាមួយនឹង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។ កិច្ចព្រមព្រៀងដែលបន្ត ៣ឆ្នាំម្តងៗជាបន្តបន្ទាប់ បានធ្វើឡើងចាប់តាំងពីឆ្នាំ១៩៩៩ ជាមួយនឹងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ហើយនឹងបន្តរហូតជាមួយក្រសួងបរិស្ថានដល់ពេលអនាគត ។ ប្រសិនបើកិច្ចព្រមព្រៀងនេះត្រូវបានបញ្ចប់ដោយផ្អែកលើឆន្ទានុសិទ្ធិរបស់ភាគីណាមួយនោះក្រសួង បរិស្ថាននឹងទទួលខុសត្រូវក្នុងការចុះកិច្ចព្រមព្រៀងដទៃទៀត ដើម្បីបំពេញតួនាទីរបស់ អង្គការសមាគមអភិរក្សសត្វព្រៃក្នុងការអនុវត្តសកម្មភាពទាំងឡាយក្នុងគម្រោងរេដបូក។

ស្ថិតក្នុងវិសាលភាពដែលអាចធ្វើបានផ្អែកលើថវិកា និង ធនធានដែលមាន អង្គការសមាគមអភិរក្សសត្វព្រៃទទួលខុសត្រូវដូចខាងក្រោម ៖

- ផ្តល់ជំបូន្មានផ្នែកបច្ចេកទេសទៅលើគ្រប់ទិដ្ឋភាពនៃការអភិរក្សនៅនឹងទីតាំង ផ្ទាល់

- ជួយធ្វើសេចក្តីព្រាងឯកសារគម្រោងមួយចំនួន ដូចជា ឯកសារអភិវឌ្ឍន៍គម្រោង របាយការណ៍ប្រចាំឆ្នាំ និង របាយការណ៍ផ្ទៀងផ្ទាត់
- គ្រប់គ្រងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលរបស់ខ្លួនផ្ទាល់ដែលចូលរួមនៅក្នុងគម្រោង
- សម្របសម្រួលការចូលរួមចំណែករបស់អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការផ្នែកអភិវឌ្ឍន៍/មុខរបរចិញ្ចឹមជីវិត
- រួមសហការដើម្បីរក្សាស្ថេរភាពថវិកាក្រៅគម្រោងរេដបូក ដែលត្រូវការសម្រាប់អាជីវកម្មដែលជាសកម្មភាពធម្មតា។

ដៃគូអនុវត្តសំខាន់ៗដទៃទៀត គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និង អន្តរជាតិដែលធ្វើការផ្នែកអភិវឌ្ឍន៍។ ដៃគូជាក់លាក់នឹងអាស្រ័យទៅលើកម្រិតថវិកា និង តម្រូវការបច្ចេកទេសរបស់គម្រោង ហើយអាចនឹងមានការប្រែប្រួលនៅក្នុងអំឡុងពេលអនុវត្តនូវគម្រោងនេះដោយផ្អែកលើមូលដ្ឋាននៃកិច្ចសន្យាដែលបានពិភាក្សាដើម្បីផ្តល់សេវានានា។ ដៃគូចម្បងក្នុងរយៈពេលប៉ុន្មានឆ្នាំនៅដើមគម្រោងនេះ គឺក្រុមអភិវឌ្ឍន៍ជនបទកម្ពុជា (CRDT)។ ក្រុមអភិវឌ្ឍន៍ជនបទកម្ពុជាបានសហការជាមួយនឹងរដ្ឋបាលព្រៃឈើ និង អង្គការសមាគមអភិរក្សសត្វព្រៃនៅក្នុងទីតាំងគម្រោងចាប់តាំងពីឆ្នាំ ២០០៥មកម្លេះ ហើយនៅក្នុងអំឡុងឆ្នាំ២០០៨-២០១០ ក្រុមអភិវឌ្ឍន៍ជនបទកម្ពុជាបានធ្វើការនៅទីនោះ ដោយមួយផ្នែកស្ថិតក្រោមការចុះកិច្ចសន្យាផ្ទាល់ជាមួយនឹងអង្គការសមាគមអភិរក្សសត្វព្រៃ។ ដៃគូដទៃទៀតដែលសហការនៅក្នុងគម្រោងនេះមានដូចជាមជ្ឈមណ្ឌលសំវាសនា (Sam Veasna Centre-SVC) គម្រោងជ្រលងដំរី (Elephant Valley Project-EVP) និង អង្គការក្តីសង្ឃឹមអន្តរជាតិ (World Hope International-WHI)។

ក្រុមអភិវឌ្ឍន៍ជនបទកម្ពុជា (CRDT) និង ដៃគូដទៃទៀតស្រដៀងគ្នានេះ នឹងទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពប្រកបរបរចិញ្ចឹមជីវិតជាក់លាក់ផ្សេងទៀត ឧទាហរណ៍ ការបង្កើតគម្រោងកសិកម្មប្រកបដោយនិរន្តរភាព ទេសចរណ៍ធម្មជាតិ និង គម្រោងលើកកម្ពស់មុខរបរក្រៅពីកសិកម្មជាដើម។ ការងារនេះពាក់ព័ន្ធជាចម្បងទៅនឹងសកម្មភាពនានាស្ថិតក្រោមអនុគោលដៅទី ៤ នៃផែនការការងារ ដោយក្នុងនោះក្រុមអភិវឌ្ឍន៍ជនបទកម្ពុជាក៏ចូលរួមក្នុងការផ្សព្វផ្សាយមួយចំនួនផងដែរ (អនុគោលដៅទី ៣ សកម្មភាពទី ៥)។

## ២. ការតាមដាន និងអនុវត្តគម្រោង

ខាងក្រោមនេះគឺការបរិយាយសង្ខេបស្តីពីការអនុវត្តនូវគម្រោងរេដបូកតំបន់ដែនជម្រកសត្វព្រៃកែវសីមាចាប់ពីឆ្នាំ ២០១០ ដល់ ២០១៥។ នៅក្នុងការរៀបចំគម្រោងនេះគោលបំណងចំនួន៤ត្រូវបានកំណត់ និងវាស់វែង តាមរយៈកិច្ចអន្តរាគមន៍ដោយផ្ទាល់ និងប្រយោល។ គោលបំណងទាំងនោះមាន៖

១. រក្សានូវភាពចម្រុះនៃប្រភេទព្រៃឈើទាំងអស់នៅក្នុងតំបន់
២. បង្កើននូវសុវត្ថិភាព និងផលិតភាពនៃធនធានធម្មជាតិ ដើម្បីគាំទ្រដល់ការចញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន
៣.មានដីស្រែចំការគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ដល់ការចញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន ដែលរួមទាំងវប្បធម៌ប្រពៃណីផងដែរ
៤. បង្កើននូវចំនួនប្រភេទសត្វព្រៃ ដែលត្រូវការអភិរក្ស

សកម្មភាពជាក់លាក់ជាមួយគោលបំណងនិមួយៗនឹងត្រូវបានរៀបរាប់នៅក្នុងផ្នែកខាងក្រោម៖

### ២.១. កិច្ចអន្តរាគមន៍ដោយផ្ទាល់

**គោលបំណង #១៖ ឯកសារផែនការ និងឯកសារច្បាប់សម្រាប់តំបន់ដែនជម្រកសត្វព្រៃកែវសីមា និងទីតាំងជុំវិញត្រូវបានអនុម័ត និង អនុវត្ត**

- សកម្មភាព #១៖ ឯកសារគាំទ្រអនុក្រឹត្យបានរក្សាទុកក្នុងចំណោមមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ និង សាធារណជនទូទៅ
- សកម្មភាព # ២៖ ផែនការគ្រប់គ្រងត្រូវបានអនុម័ត និងត្រូវអនុវត្ត(រួមមានការកំណត់តំបន់ និងបទបញ្ជា)
- សកម្មភាព #៣៖ អនុវត្តន៍យុទ្ធសាស្រ្តច្រករបៀងក្នុងខេត្តមណ្ឌលគីរី
- សកម្មភាព#៤៖ ការបង្កើតភាពជាដៃគូជាមួយផ្នែកឯកជន (ដើម្បីកាត់បន្ថយផលប៉ះពាល់បង្កឡើងដោយក្រុមហ៊ុន)
- សកម្មភាព # ៥ ៖ រៀបចំកិច្ចពិភាក្សាអំពី ការឆ្លងកាត់ព្រំដែនអន្តរជាតិ
- សកម្មភាព #៦៖ អនុវត្តការគ្រប់គ្រងដែល បត់បែនតាមស្ថានភាព

ក្រុមនៃសកម្មភាពនេះចូលរួមដោះស្រាយការគម្រាមកំហែងដោយប្រយោលនូវភាពទន់ ខ្សោយនៃច្បាប់ និងព្រំដែនមិនបានកំណត់ និងបទប្បញ្ញត្តិផ្សេងសម្រាប់តំបន់នេះ។

អនុក្រឹត្យ ១៤៣ ត្រូវបានអនុម័តក្នុងឆ្នាំ២០១០ ហើយត្រូវបានចែកចាយទៅឲ្យសហគមន៍មូលដ្ឋាន និងដៃគូរពាក់ព័ន្ធ ។ បន្ថែមពីនេះទៀត ក្រុមការងាររបស់គម្រោងបានគាំទ្រ ការងាររបស់គម្រោងរេដបូកនៅតំបន់ដែនជម្រកសត្វព្រៃកែវសីមា តាមរយៈកិច្ចប្រជុំផ្សេងៗ សិក្ខាសាលាជាតិ និងកម្រិតតំបន់ ប្រព័ន្ធផ្សព្វផ្សាយ (ឧ. វីដេអូ ព្រឹត្តិបត្រ និងករណីសិក្សា)។ ដំណើរទស្សនៈកិច្ចជាច្រើនបានរៀបចំឡើងនៅដែនជម្រកសត្វព្រៃកែវសីមា សម្រាប់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ និងអ្នកផ្សេងៗទៀតក្នុងការលើកកម្ពស់ ចំណេះដឹងដល់សាធារណជនទូទៅ។ ខិតបណ្ណ័រេដបូកនៃដែនជម្រកសត្វព្រៃកែវសីមាត្រូវបានចងក្រងឡើងនឹងបានចែកជូនទៅភាគីពាក់ព័ន្ធ។ សេចក្តីសង្ខេបនៃឯកសាររៀបចំគម្រោងត្រូវបានបកប្រែជា ភាសាខ្មែរ និង ចែកចាយ ទៅឲ្យភាគីពាក់ព័ន្ធនៅក្នុងគម្រោងព្រមជាមួយនឹងវីដេអូខ្លីៗ អំពីការប្រែប្រួលអាកាសធាតុ និងរេដបូក។

ជារួមការការពារផ្នែកច្បាប់សម្រាប់តំបន់នេះត្រូវបានជម្រុញតាំងពីដំបូង នៅក្នុងគម្រោងនេះ តាមរយៈការចងក្រងផែនការគ្រប់គ្រងតំបន់ទេសភាពជាមួយនឹងការកំណត់តំបន់ និងបទដ្ឋានច្បាប់ រួមទាំងដែនជម្រកសត្វព្រៃកែវសីមា ដែលត្រូវបានហៅថា ព្រៃទេសភាពភាគខាងកើត។ ផែនការថ្នាក់ខេត្តនេះ ជួយរក្សាតំណភ្ជាប់តំបន់ដែនជម្រកសត្វព្រៃកែវសីមា ជាមួយនឹងតំបន់ព្រៃដ៏ទៃទៀត និងជាព័ត៌មានក្នុងការរៀបចំព្រៃច្រកល្បៀងទូទាំងប្រទេស ដែលចងក្រងដោយក្រសួងបរិស្ថាន ហើយសង្ឃឹមថានឹងដាក់ឲ្យអនុវត្តនៅក្នុងឆ្នាំ ២០១៧។

ការបន្តនូវកិច្ចពិភាក្សា ត្រូវបានរក្សាការភ្ជាប់ជាមួយភាគីវិស័យឯកជន និងអជ្ញាធរឆ្លងដែន ក្នុងការកាត់បន្ថយការគម្រាមកំហែងជាក់លាក់មួយចំនួន។ប្រធានគម្រោងដែនជម្រកសត្វព្រៃកែវសីមា ចូលរួមប្រជុំថ្នាក់ខេត្ត និងស្រុកជាទៀងទាត់ ដែលរួមទាំងភាគីពាក់ព័ន្ធផ្សេងៗ។ ជាងនេះទៅទៀត កិច្ចប្រជុំជាទៀងទាត់ជាមួយភាគីវៀតណាម នៅក្នុងឧទ្យានជាតិ ប៊ូ ស្សី ម៉ាត(Bu Gia Map) ដែលមានព្រំប្រទល់ជាប់ជាមួយដែនជម្រកសត្វព្រៃកែវសីមាត្រូវបានប្រារព្ធឡើង ដើម្បីពិភាក្សា កិច្ចសហប្រតិបត្តការ ក្នុងការដោះស្រាយ បញ្ហាបទល្មើសព្រៃឈើ និងការជួញដូរសត្វព្រៃឆ្លងព្រំដែន។ កិច្ចប្រជុំប្រចាំឆ្នាំ ជាមួយភាគីពាក់ព័ន្ធជាសារធារណៈ ការពិគ្រោះយោបល់សហគមន៍ និងសកម្មភាពតាមដាន ដែលកំពុងធ្វើឡើង ផ្តល់ពត៌មានដល់ការបង្កើតនូវផែនការប្រចាំឆ្នាំ ហើយនឹងជួយសម្រួលក្នុងការគ្រប់គ្រងដែលមានភាពបន់បែន។ សកម្មភាពសំខាន់ៗនៅក្នុង គោលបំណង ១៖ "ឯកសា

ផែនការ និងឯកសារច្បាប់សម្រាប់ដែនជម្រកសត្វព្រៃកែវសីមា និង ទីតាំងជុំវិញត្រូវបាន អនុម័ត និង អនុវត្ត ដែលត្រូវបានសង្ខេបក្នុងតារាងខាងក្រោម ។

| គោលបំណងរងទី ១ | សកម្មភាពសំខាន់ៗ | ស្ថានភាព |
|---|---|---|
| សកម្មភាព #១៖ ឯកសារគាំទ្រ អនុក្រឹត្យបានរក្សាទុកក្នុងចំណោមមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ និង សាធារណជនទូទៅ | • អនុក្រិត្យព្រៃការពារសីមាបានអនុម័ត ឆ្នាំ២០១០<br>• អនុក្រិត្យដែនជម្រកសត្វព្រៃកែវសីមាឆ្នាំ ២០១៦<br>• អនុក្រិត្យជាភាសាខ្មែរបានចែកចាយទៅឲ្យតំណាងសហគមន៍មូលដ្ឋាន និងដៃគូរ | បញ្ចប់ |
| | • គាំទ្រការងារគម្រោងរេដបូកនៅតំបន់ដែនជម្រកសត្វព្រៃកែវសីមា តាមរយៈ កិច្ចប្រជុំផ្សេងៗ សិក្ខាសាលា ប្រព័ន្ធផ្សព្វផ្សាយ (ឧ. វីដេអូ ព្រឹត្តិបត្រ និងករណីសិក្សា)<br>• ផ្សព្វផ្សាយ ខិត្តបណ្ណ័ឯកសារគម្រោង និងវីដេអូ អំពីគម្រោងរេដបូកនៅដែនជម្រកសត្វព្រៃកែវសីមា | កំពុងអនុវត្ត |
| សកម្មភាព #២៖ ផែនការគ្រប់គ្រងត្រូវបានអនុម័ត និង ត្រូវអនុវត្ត | • ផែនការគ្រប់គ្រងសម្រាប់ព្រៃទេសភាពភាគខាងកើតបានបង្កើតនៅឆ្នាំ២០១០ | បញ្ចប់ |
| | • ដែនជម្រកសត្វព្រៃកែវសីមាបង្កើតផែនការគ្រប់គ្រងប្រចាំឆ្នាំស្របទៅនឹងការកំណត់តំបន់ដែលបានកំណត់ក្នុងរបាយការណ៍គម្រោង(PD) | កំពុងអនុវត្ត |
| សកម្មភាព #៣៖ អនុវត្តន៍យុទ្ធសាស្ត្រ ប្រករបៀងក្នុងខេត្តមណ្ឌលគីរី | • កិច្ចពិភាក្សាជាមួយភាគីពាក់ព័ន្ធនៅថ្នាក់ខេត្ត | កំពុងអនុវត្ត |
| សកម្មភាព #៤៖ ការបង្កើតភាពជាដៃគូជាមួយផ្នែកឯកជន | • ចូលរួមប្រជុំជាប្រចាំនៅថ្នាក់ខេត្ត និងស្រុកជាមួយសាធារណជន និងភាគីឯកជន | កំពុងអនុវត្ត |
| សកម្មភាព #៥៖ រៀបចំកិច្ចពិភាក្សាអំពី ការឆ្លងកាត់ព្រំដែនអន្តរជាតិ | • កិច្ចប្រជុំជាប្រចាំជាមួយគូភាគីវៀតណាមក្នុងឧទ្យានជាតិ ប៊ូ ស្សី ម៉ាត(Bu Gia Map)ដើម្បីពិភាក្សា កិច្ចសហប្រតិបត្តការ តាមព្រំដែន លើបញ្ហាបទល្មើសព្រៃឈើនិងការជួញដូរសត្វព្រៃ | កំពុងអនុវត្ត |
| សកម្មភាព #៦៖អនុវត្តការគ្រប់គ្រងដែល បត់បែនតាមស្ថានភាព | • កិច្ចប្រជុំជាប្រចាំក្នុងការកែសម្រួលសកម្មភាព និងផែនការ<br>• សិក្ខាសាលាផែនការប្រចាំឆ្នាំ (២០១៦, ២០១៧) | កំពុងអនុវត្ត |

រូបភាពទី 2 **កិច្ចប្រជុំទ្វេភាគី និងវគ្គបណ្តុះបណ្តាលស្តីពីការប្រឆាំងការជួញដូរសត្វព្រៃ**




**គោលបំណង #២៖កាត់បន្ថយបទល្មើសសត្វព្រៃ និង ព្រៃឈើតាមរយៈការគោរពច្បាប់ដោយផ្ទាល់**

- សកម្មភាព #១៖ ជំរុញការអនុវត្តច្បាប់ និង អនុក្រឹត្យស្តីពី សត្វព្រៃ ព្រៃឈើ និងតំបន់ការពារ តាមរយៈការយាមល្បាត
- សកម្មភាព #២៖ បង្កើត និង អនុវត្តក្របខ័ណ្ឌ តាមដានការអនុវត្តច្បាប់
- សកម្មភាព #៣ ៖ ធានាឱ្យមានស្នាក់ការល្បាត បរិក្ខារ និង បុគ្គលិកគ្រប់គ្រាន់
- សកម្មភាព # ៤ ៖ ធានាសមត្ថភាព គ្រប់គ្រាន់សម្រាប់បុគ្គលិកល្បាត
- សកម្មភាព #៥៖ទំនាក់ទំនងជាមួយ អាជ្ញាធរខេត្ត អាជ្ញាធរជាតិ និងអាជ្ញាធរដទៃទៀត
- សកម្មភាព #៦៖ បង្កើតប្រព័ន្ធតាមដាន និង/ឬ ល្បាតនៅតាមសហគមន៍

ក្រុមនៃសកម្មភាពនេះជាចំនុចកណ្តាលក្នុងការគាំទ្រទៅក្រុមពង្រឹងការអនុវត្តច្បាប់ដែលដឹកនាំដោយមន្ត្រីរដ្ឋាភិបាល ដែលជាក្រុមដែលដឹកនាំល្បាតផ្ទាល់ផ្សព្វផ្សាយច្បាប់ទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធ និងសកម្មភាពប្រមូលរបាយការណ៍សម្ងាត់។ សកម្មភាពល្បាត និងលទ្ធផល ត្រូវបានគ្រប់គ្រងដោយប្រើប្រាស់ឧបករណ៍សម្រាប់ធ្វើការត្រួតពិនិត្យ និងរាយការណ៍ព័ត៌មានអំពីទីតាំងភូមិសាស្ត្រ (SMART) ដែលផ្តល់ទាំងទិន្នន័យកំពុងដំណើរ ការនៃការកត់ត្រានូវសកម្មភាពបទល្មើសនៅក្នុងតំបន់ និងសម្រាប់រៀបចំគោលដៅល្បាត។ តំបន់ដែនជម្រកសត្វព្រៃកែវសីមា បានរក្សានូវសកម្មភាពល្បាតជាទៀងទាត់ចាប់តាំងពីការចាប់ផ្តើមនៃគម្រោងរេដបូក។ គម្រោងបានចូល

រួមដោះស្រាយការគម្រាមកំហែងដោយផ្ទាល់ ដែលបណ្តាលមកពីការកាប់ឆ្ការព្រៃឈើ/ ទន្ទ្រានដីព្រៃដោយបុគ្គល ការនេសាទលើសកំណត់ ការបរបាញ់សត្វព្រៃលើសកំណត់ កាប់ព្រៃខុសច្បាប់ និងការដកហូតអនុផលព្រៃឈើដ៏លើសលប់ ហើយនឹងការគម្រាមកំហែងដោយប្រយោលនៃការចំណាកស្រុកខុសច្បាប់ ដែលជាលទ្ធផលនឹងទទួលនូវការកាត់បន្ថយ ការគម្រាមកំហែងនៃការផ្ទេរសិទ្ធដីធ្លី និងទំនាស់ផ្នែកច្បាប់ទាក់ទងនឹងដី។

## សកម្មភាពសំខាន់ៗនៅក្នុងគោលបំណង២៖ "កាត់បន្ថយបទល្មើសសត្វព្រៃ និង ព្រៃឈើពង្រឹងលើការអនុវត្តច្បាប់ដោយផ្ទាល់"

| គោលបំណង #២ | សកម្មភាពសំខាន់ៗ | ស្ថានភាព |
|---|---|---|
| សកម្មភាព #១៖ ជំរុញការអនុវត្តច្បាប់ និង អនុក្រឹត្យស្តីពីព្រៃឈើ តំបន់ការពារ និង សត្វព្រៃតាមរយៈការយាមល្បាត | • ការយាមល្បាតធម្មតាដោយថ្មើរជើង និងរថយន្តល្បាត | កំពុងបន្ត |
| សកម្មភាព #២៖ បង្កើត និង អនុវត្តក្របខ័ណ្ឌ តាមដានការអនុវត្តច្បាប់ | • ឧបករណ៍សម្រាប់ធ្វើការត្រួតពិនិត្យ និងរាយការណ៍ព័ត៌មានអំពីទីតាំងភូមិសាស្ត្រ (SMART) នៅកន្លែង និងប្រើសម្រាប់តាមដាន សកម្មភាពល្បាត | កំពុងបន្ត |
